# តួនាទីរបស់មន្ត្រីកិច្ចសន្យា
# និង
# ការផ្ទេរចំណេះដឹង

បង្ហាញដោយ

---

## មាតិកា

1. អំពីមន្ត្រីកិច្ចសន្យា
2. អំពីការផ្ទេរចំណេះដឹង
3. វដ្តនៃការផ្ទេរចំណេះដឹង

# ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

## ១. អំពីមន្ត្រីកិច្ចសន្យា



- ទីប្រឹក្សាគ្រប់គ្រងកម្មវិធី
- ទីប្រឹក្សាគោលនយោបាយ
- ទីប្រឹក្សាគោលនយោបាយអភិវឌ្ឍសមត្ថភាព
- ទីប្រឹក្សាអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា
- ទីប្រឹក្សាគោលនយោបាយយេនឌ័រ
- ទីប្រឹក្សាគោលនយោបាយផែនការថ្នាក់ក្រោមជាតិ
- ទីប្រឹក្សាគោលនយោបាយវិមជ្ឈការសារពើពន្ធថ្នាក់ក្រោមជាតិ
- ទីប្រឹក្សាគោលនយោបាយមុខងារ
- ទីប្រឹក្សាគោលនយោបាយស្រាវជ្រាវ និងវាយតម្លៃ
- ទីប្រឹក្សាផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
- ទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃ
- ទីប្រឹក្សាសេវាកម្មថ្នាក់ក្រោមជាតិ
- ទីប្រឹក្សាហិរញ្ញវត្ថុ
- ទីប្រឹក្សាផ្នែកព័ត៌មានវិទ្យា
- ទីប្រឹក្សាផ្នែកគ្រប់គ្រងធនធានមនុស្ស
- ទីប្រឹក្សាអភិវឌ្ឍសមត្ថភាព
- ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ
- ទីប្រឹក្សារដ្ឋបាល និងហិរញ្ញវត្ថុ
- ទីប្រឹក្សាក្រុមការងារគណនេយ្យភាព
- ទីប្រឹក្សាគោលនយោបាយធនធានមនុស្ស
- ទីប្រឹក្សាប្រព័ន្ធផែនការថ្នាក់ក្រោមជាតិ



- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត
- ទីប្រឹក្សាតាមដានត្រួតពិនិត្យ និងវាយតម្លៃ
- ទីប្រឹក្សាហិរញ្ញវត្ថុ
- ទីប្រឹក្សាអភិវឌ្ឍសមត្ថភាព
- ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ
- មន្ត្រីសម្របសម្រួលក្រុមប្រឹក្សា



- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ក្រុង ស្រុក ខណ្ឌ
- មន្ត្រីសម្របសម្រួលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

# ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

ភាពរីកចម្រើនផ្នែកសមត្ថភាពរបស់មន្ត្រីរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺជាសូចនាករមួយយ៉ាងសំខាន់សម្រាប់ វាស់វែងសមត្ថភាពរបស់ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាដែលបម្រើការងារជាមួយ ។

# ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

## ២. អំពីការផ្ទេរចំណេះដឹង

**តើការផ្ទេរចំណេះដឹងមានន័យយ៉ាងដូចម្តេច?**

**ហេតុអ្វីចាំបាច់ត្រូវផ្ទេរចំណេះដឹងពីមន្ត្រីកិច្ចសន្យាទៅមន្ត្រីរាជរដ្ឋាភិបាល?**

# ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

**ចំណេះដឹង**

↓

**ការផ្ទេរចំណេះដឹង**

***“ចំណេះដឹង”*** សំដៅទៅលើសមត្ថភាពរបស់បុគ្គល សម្រាប់អនុវត្ត សកម្មភាព ឬការធ្វើសេចក្តីសម្រេចនានាដែលមានប្រសិទ្ធិភាព ដែលនឹងជួយសម្រេចបាននូវសមិទ្ធិផល និងប្រសិទ្ធិភាពការងាររបស់បុគ្គល និងស្ថាប័ន។

***“ការផ្ទេរចំណេះដឹង”*** សំដៅទៅលើដំណើរការនៃការចែករំលែក ឬ ការផ្តល់ចំណេះដឹងពីបុគ្គលម្នាក់ទៅម្នាក់ទៀតក្នុងការអនុវត្តសកម្មភាពនានាប្រកបដោយប្រសិទ្ធភាព។

# ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

## ២. អំពីការផ្ទេរចំណេះដឹង

**គោលបំណង**

ដើម្បីពង្រឹង និងអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ភាពជាម្ចាស់ និងធានានូវនិរន្តរភាពនៃការអនុវត្តភារកិច្ចនៃកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

## ២. អំពីការផ្ទេរចំណេះដឹង

**សារៈសំខាន់**

- ផ្តល់ចំណេះដឹងមន្ត្រីរាជរដ្ឋាភិបាលក្នុងការអនុវត្តតួនាទីភារកិច្ចក្នុងមុខតំណែងជាក់លាក់របស់ខ្លួន
- កាត់បន្ថយជាបណ្តើរៗនូវការពឹងផ្អែកលើទីប្រឹក្សា និងមន្ត្រីកិច្ចសន្យា
- ចៀសវាងបាននូវការបាត់បង់ចំណេះដឹងរបស់មន្ត្រីកិច្ចសន្យា នៅពេលមន្ត្រីនោះលាឈប់
- ធានាបាននូវការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រី
- លើកកម្ពស់ភាពជាម្ចាស់ និងធានានិរន្តរភាពក្នុងការដឹកនាំ ចាត់ចែង និងអនុវត្តកំណែទម្រង់

# ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

## ៣. វដ្តនៃការផ្ទេរចំណេះដឹង




# ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

## ការពិភាក្សាដៃគូ (នាយករដ្ឋបាល ទីប្រឹក្សា)

តើនរណាជាដៃគូរបស់ទីប្រឹក្សា...............?

ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ
ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់រាជធានី ខេត្ត ឬ
មន្ត្រីសម្របសម្រួលក្រុមប្រឹក្សារាជធានី ខេត្ត

# ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា




- ដើម្បីមានមូលដ្ឋាន ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យានីមួយៗត្រូវកំណត់ឱ្យបានច្បាស់អំពីដៃគូរបស់ខ្លួនសម្រាប់ការអភិវឌ្ឍសមត្ថភាព។
- ការកំណត់ដៃគូបានច្បាស់អាចជួយឱ្យទីប្រឹក្សា និងមន្ត្រីកិច្ចសន្យានីមួយៗអាចងាយស្រួលក្នុងការកំណត់អំពីតម្រូវការ និងវិធីសាស្ត្រផងដែរ។

# ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា



# ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

**ការពិនិត្យមើលអំពីតួនាទីភារកិច្ច**

- ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យានីមួយៗ ត្រូវពិនិត្យមើលអំពីតួនាទីភារកិច្ចរបស់ដៃគូ ឬរបស់ស្ថាប័នគោលដៅនីមួយៗដែលត្រូវបំពេញ។
- តាមរយៈការពិនិត្យលើតួនាទី ភារកិច្ចនេះ ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាអាចដឹងថា ដើម្បីអនុវត្តតួនាទី ភារកិច្ចទាំងនោះ តើដៃគូរបស់ខ្លួនត្រូវការអភិវឌ្ឍសមត្ថភាពផ្នែកអ្វី? តើបច្ចុប្បន្នដៃគូរបស់ខ្លួនមានសមត្ថភាពអ្វីខ្លះ? នៅខ្វះអ្វីទៀត? ជាដើម។

↓

**កំណត់បានអំពី តម្រូវការសមត្ថភាពដើម្បីតួនាទីភារកិច្ចរបស់ដៃគូ**

# ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

**ការអង្កេតការអនុវត្ត**

តាមរយៈការអនុវត្តការងារប្រចាំថ្ងៃ ទីប្រឹក្សា ឬមន្ត្រីកិច្ចសន្យាអាចសង្កេត និងអាចកំណត់បានថា តើដៃគូរបស់ខ្លួនមានសមត្ថភាពកម្រិតណាក្នុងការអនុវត្តការងាររបស់ខ្លួន? តើដៃគូនៅខ្វះសមត្ថភាពផ្នែកអ្វីទៀត?

↓

**កំណត់បានអំពី តម្រូវការសមត្ថភាពដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងារប្រចាំថ្ងៃ**

## ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

ការពិនិត្យមើលប្រតិទិន

នៅក្នុងការអនុវត្តកិច្ចការប្រចាំថ្ងៃ ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាត្រូវដឹងអំពីប្រតិទិនការងាររបស់ការិយាល័យ ឬអង្គភាពខ្លួនដែលត្រូវបំពេញ ឬគាំទ្រ។

↓

កំណត់បានអំពី តម្រូវការសមត្ថភាពក្នុងការអនុវត្តភារកិច្ចតាមប្រតិទិននោះ

## ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

ការពិគ្រោះយោបល់

ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាក៏អាចកំណត់អំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់ដៃគូតាមរយៈការពិភាក្សា និងការពិគ្រោះយោបល់ជាមួយគ្នា។ ចំណុចសំខាន់ៗក្នុងការពិគ្រោះពិភាក្សាមានដូចជា លទ្ធផលនៃការអនុវត្តការងារ ការលំបាក បញ្ហាប្រឈម ឬការដោះស្រាយបញ្ហាជាដើម។

↓

កំណត់បានអំពី តម្រូវការសមត្ថភាពសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា

# ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា




**តារាងគំរូទី២**

**ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាព**

ប្រចាំ......................

| ល.រ | សមត្ថភាព | វិធីសាស្ត្រ | ពេលវេលា | ក្រុមគោលដៅ | ផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

# ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា



## ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

**ការបណ្ដុះបណ្ដាល**

- ត្រូវអនុវត្តដោយមានការសម្របសម្រួល បង្ហាត់បង្ហាញពីអ្នកមានចំណេះដឹងទៅសិក្ខាកាម។
- ភាគច្រើនរៀបចំឡើងដើម្បីផ្តល់នូវចំណេះដឹង ជំនាញថ្មីៗ និងមានលក្ខណៈផ្លូវការច្រើន។
- មានសារៈសំខាន់ក្នុងការផ្តល់នូវព័ត៌មានដល់អ្នកចូលរួមបានច្រើនក្នុងពេលតែមួយនូវប្រភេទចំណេះដឹង ជំនាញឬមានតែមួយ។

- មន្ត្រីកិច្ចសន្យាអាចរៀបចំការបណ្តុះបណ្តាលលើប្រធានបទជាក់លាក់ណាមួយដល់ក្រុមគោលដៅរបស់ខ្លួន ដែលមានរយៈពេល០១ព្រឹក ឬ០១ថ្ងៃ ឬយូរ ឬឆាប់ជាងនេះតាមជាក់ស្តែង។

## ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

**សិក្ខាសាលា**

- ជាវិធីសាស្ត្រមួយក្នុងការផ្ទេរ និងចែករំលែកចំណេះដឹង ដោយការផ្តល់ឱកាសដល់អ្នកចូលរួមក្នុងដំណើរការពិភាក្សា ស្វែងយល់រៀនសូត្រតាមរយៈការបង្ហាញនូវបទពិសោធន៍ លទ្ធផលនៃការអនុវត្ត ឬការស្រាវជ្រាវ ដោយមានការពិភាក្សាលើបញ្ហា រកដំណោះស្រាយ និងការបកស្រាយពន្យល់ផ្សេងៗលើប្រធានបទណាមួយ។

- មន្ត្រីកិច្ចសន្យាអាចរៀបចំសិក្ខាសាលាលើប្រធានបទជាក់លាក់ណាមួយដល់ក្រុមគោលដៅរបស់ខ្លួន ដោយអញ្ជើញអ្នកចូលរួមដែលពាក់ព័ន្ធ និងអ្នកដែលមានបទពិសោធ មកពិភាក្សា ឆ្លុះបញ្ចាំង និងរកដំណោះស្រាយ។

## ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

ការផ្តល់យោបល់

- អ្នកផ្តល់យោបល់នឹងផ្តល់ជាជម្រើសនានា ដល់ក្រុមគោលដៅរបស់ខ្លួន ហើយ
- ក្រុមគោលដៅនោះ គឺជាអ្នកសម្រេច។
- ដើម្បីអនុវត្តវិធីសាស្ត្រនេះបានទាមទារឲអ្នកផ្តល់យោបល់មានជំនាញបច្ចេកទេសខ្ពស់ក្នុងការបង្កើតជម្រើសនានាឲ្យដៃគូរបស់ខ្លួន។

ក្នុងការអនុវត្តជាក់ស្តែង មន្ត្រីកិច្ចសន្យាអាចជួយអភិវឌ្ឍសមត្ថភាពដល់ដៃគូរបស់ខ្លួនតាមរយៈការផ្តល់យោបល់ជូនពួកគាត់ ដោយពន្យល់ បកស្រាយ និងបង្ហាញអំពីគុណសម្បត្តិ និងគុណវិបត្តិនៃជម្រើសនីមួយៗដែលខ្លួនបានលើកឡើង។

## ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

ការប្រឹក្សាយោបល់

- ដំណើរការនៃ CD ដល់បុគ្គល ឬក្រុមគោលដៅជាក់លាក់មួយក្នុងការដោះស្រាយបញ្ហា ឬអនុវត្តភារកិច្ចជាក់លាក់ណាមួយតាមរយៈការសួរសំណួរបំផុស និងការនាំឲ្យក្រុមគោលដៅនីមួយៗគិតដោយខ្លួនឯងអំពីជម្រើស និងដំណោះស្រាយ។
- ផ្តល់សេវាប្រឹក្សាយោបល់អាចជួយដៃគូរបស់ខ្លួនក្នុងការដោះស្រាយបញ្ហានានារបស់ពួកគេបានដោយខ្លួនឯង។

- មន្ត្រីកិច្ចសន្យាត្រូវមានចំណេះ ដឹង និងការយល់ដឹងអំពីដំណើរការនៃការផ្តល់ប្រឹក្សាយោបល់
- អនុវត្តវិធីសាស្ត្រនេះភាគច្រើនមានលក្ខណៈមិនផ្លូវការ ចំណាយថវិកាតិច ប្រើពេលវេលាខ្លី ប៉ុន្តែត្រូវអនុវត្តជាទៀងទាត់។

## ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

ការរៀនសូត្រពីការអនុវត្ត

- គឺជាដំណើរការផ្ទេរចំណេះដឹង ដែលត្រូវអនុវត្តជាក់ស្តែងនៅកន្លែងការងារផ្ទាល់តែម្តង។
- កើតឡើងរវាងអ្នកដែលមានចំណេះដឹង ឬបទពិសោធន៍ច្រើនបង្រៀន ឬណែនាំផ្ទាល់ដល់អ្នកដែលមានចំណេះដឹង និងបទពិសោធន៍តិចជាងនៅក្នុងការអនុវត្ត ការងារជាក់ស្តែង។

- តាមរយៈធ្វើការងារជាមួយគ្នា មន្ត្រីកិច្ចសន្យាអាចដឹងពីចំណុចខ្វះខាតរបស់ក្រុមគោលដៅ ហើយអាចផ្តល់នូវយោ បល់ ឬការណែនាំកែលម្អភ្លាមៗ។

## ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

ការឆ្លុះបញ្ចាំង

- ជាការពិនិត្យមើលឡើងវិញនូវកិច្ចការដែលបានអនុវត្តរួច
- ជាវិធីសាស្ត្រមួយក្នុងការផ្ទេរចំណេះដឹង ឬបទពិសោធន៍ ដោយការពិភាក្សាក្នុងចំណោមអ្នកពាក់ព័ន្ធដែលបានអនុវត្តសកម្មភាព ឬធ្វើកិច្ចការអ្វីមួយ។
- វិធីសាស្ត្រនេះអនុញ្ញាតឱ្យអ្នកចូលរួមម្នាក់ៗបានរៀនសូត្រ ស្វែងយល់ និងពិនិត្យមើលនូវអ្វីជាចំនុចខ្លាំង និងចំនុចខ្វះខាតដែលត្រូវកែលម្អនៅពេលក្រោយ។

- ទីប្រឹក្សា មន្ត្រីកិច្ចសន្យា អាចបំពេញតួនាទីជាអ្នកសម្របសម្រួលក្នុងការពិភាក្សា និងមានការកត់ត្រានូវបញ្ហាផ្សេងៗ។

# ៤.ការអនុវត្តតួនាទីរបស់មន្ត្រីកិច្ចសន្យា

បន្ទាប់ពីអន្តរាគមន៍អភិវឌ្ឍសមត្ថភាព ចាំបាច់ត្រូវរៀបចំការវាយតម្លៃនូវភាពរីកចម្រើនផ្នែកសមត្ថភាពរបស់ដៃគូ។




លទ្ធផលនៃការវាយតម្លៃអំពីការអភិវឌ្ឍសមត្ថភាពនេះ អាចនឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋាន ក្នុងការវាយតម្លៃការអនុវត្តការងាររបស់មន្ត្រីកិច្ចសន្យាប្រចាំឆ្នាំ និងក៏អាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់រៀបចំផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពដល់ដៃគូក្នុងពេលក្រោយទៀត។






# អរគុណ!